# សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និង លើកទិសដៅការងារឆ្នាំ២០២៤របស់ក្រសួងផែនការ

## លទ្ធផលការងារឆ្នាំ២០២៣
## និងទិសដៅឆ្នាំ២០២៤ លើការងារផែនការ

ដោយ ឯកឧត្តម ថេង បញ្ញាធន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការ
ក្រសួងផែនការថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤

# មាតិកា

១. សេចក្តីផ្តើម

២. ការងាររៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ

៣. ការងាររៀបចំ កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល

៤. ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.)

៥. ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

៦. ការងារអាហារូបត្ថម្ភ

៧. ការងារផែនការនៅថ្នាក់ក្រោមជាតិ

៨. ការងារវាស់វែងភាពក្រីក្រ របស់ប្រជាជន និងកុមារកម្ពុជា

៩. ទិសដៅត្រូវអនុវត្តបន្តឆ្នាំ២០២៤

# ១. សេចក្ដីផ្ដើម

- អគ្គនាយកដ្ឋានផែនការ គឺជាអង្គភាពយ៉ាងសំខាន់ក្នុងក្រសួងផែនការ មានភារកិច្ចៈ
  - រៀបចំគោលនយោបាយ យុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែង និង កម្មវិធីជាតិសម្រាប់អភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។
  - ពិនិត្យរាល់អនុសញ្ញា និងកម្មវិធីអន្តរជាតិនានា ដែលកម្ពុជាមានភារកិច្ចចូលរួមអនុវត្ត ក្នុងនាមជាសមាជិករបស់អង្គការសហប្រជាជាតិ ដើម្បីធ្វើមូលដ្ឋានីយកម្ម និងបញ្ជ្រាបទៅក្នុងផែនការជាតិ។
  - កំណត់អាទិភាពក្នុងការវិនិយោគ ទាំងសាធារណៈ និងឯកជន តាមរយៈកម្មវិធីវិនិយោគដសាធារណៈ បីឆ្នាំរំកិល។
  - តាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកម្មវិធីជាតិ។
  - ដឹកនាំ និងរៀបចំវិធីសាស្ត្រនិងអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ដើម្បីជាមូលដ្ឋានរៀបចំគោលនយោបាយ និងផែនការនៅគ្រប់កម្រិត។
  - រៀបចំនិងដឹកនាំការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រលើកកម្ពស់អាហារូបត្ថម្ភ

## ២. ការរៀបចំ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ

- ផ.យ.អ.ជ. គឺជាឯកសារផែនការយ៉ាងសំខាន់សម្រាប់អនុវត្ត គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា គោលដៅ អនុសញ្ញាសាកលដែលកម្ពុជាបានផ្តល់សច្ចាប័ន ជាពិសេស សម្រាប់អភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

- ការងាររៀបចំ ផ.យ.អ.ជ. តម្រូវឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធពីក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ។

- ផ.យ.អ.ជ. ត្រូវទទួលការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា ទទួលការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា) ហើយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នឹងឡាយព្រះហស្តលេខាលើព្រះរាជក្រម ដើម្បីដាក់ឯកសារផែនការនេះឱ្យអនុវត្តជាផ្លូវការ។

- ផែនការជាតិត្រូវបានរៀបចំចំនួន៥លើករួចមក និងធ្វើបច្ចុប្បន្នភាពមួយលើក (២០០៦-២០១០ ទៅជា ២០០៩-២០១៣)។

# ២. ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ត)

## ប្រវត្តិនៃការរៀបចំ

- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី១ (ផ.អ.ស.ស.១) ១៩៩៦-២០០០ *(១៩៩៣-១៩៩៨)*
- ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី២ (ផ.អ.ស.ស.២) ២០០១-២០០៥ *(១៩៩៨-២០០៣)*
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផ.យ.អ.ជ.) ២០០៦-២០១០ *(២០០៣-២០០៨)*
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផ.យ.អ.ជ.) បច្ចុប្បន្នកម្ម ២០០៩-២០១៣ *(២០០៨-២០១៣)*

## ២. ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ត)

### ប្រវត្តិនៃការរៀបចំ (ត)

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៤-២០១៨ *(២០១៣-២០១៨)*
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ *(២០១៨-២០២៣)*
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០២៤-២០២៨ *(២០២៣-២០២៨)* (កំពុងដំណើរការរៀបចំ)

# ២. ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ត)

## ដំណើរការរៀបចំ

- ត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំចុងក្រោយនៃអាណត្តិកាលផែនការនីមួយៗ
- ខែមករា ក្រសួងផែនការរៀបចំគោលការណ៍ណែនាំដល់ក្រសួងស្ថាប័ន សម្រាប់ការរៀបចំធាតុចូលសម្រាប់ការរៀបចំ ផ.យ.អ.ជ.
- ខែមីនា អគ្គនាយកដ្ឋានផែនការ រៀបចំសិក្ខាសាលាដើម្បីណែនាំពីការរៀបចំធាតុចូល ផ្តល់មកក្រសួងផែនការ។
- ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ត្រូវផ្តល់ធាតុចូលមកក្រសួងផែនការ ត្រឹមថ្ងៃទី ខែមេសា។

## ២. ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ត)

### ដំណើរការរៀបចំ

- ក្រសួងផែនការចាប់ផ្តើមរៀបចំសេចក្តីព្រាងដំបូងនៃ ផ.យ.អ.ជ.។
- ក្រសួងផែនការ សម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍកម្ពុជា នៃ គ.ជ.នា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីពិនិត្យ និងទទួលការណែនាំនយោបាយ លើសេចក្តីព្រាងដំបូង (ខែឧសភា)។
- ក្រសួងផែនការ ផ្ញើសេចក្តីព្រាងដំបូងទៅក្រសួង ស្ថាប័ន និងអ្នកមានចំណែកពាក់ព័ន្ធដើម្បីផ្តល់អនុសាសន៍ (ខែឧសភា)។
- ក្រសួង ស្ថាប័ន ផ្តល់អនុសាសន៍មកក្រសួងផែនការត្រឹមខែមិថុនា។

## ២. ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ត)

### ដំណើរការរៀបចំ

- រៀបចំកិច្ចប្រជុំដាច់ដោយឡែក ជាមួយអង្គការសង្គមស៊ីវិល។ (មិថុនា)
- ក្រសួងផែនការរៀបចំកិច្ចប្រជុំអន្តរក្រសួង កម្រិតបច្ចេកទេស និងនយោបាយ ពិភាក្សា និងផ្តល់ការឯកភាពលើសេចក្តីព្រាង ផ.យ.អ.ជ.។ (មិថុនា)
- ក្រសួងផែនការរៀបចំសេចក្តីព្រាងចុងក្រោយ នៃ ផ.យ.អ.ជ. ២០២៤-២០២៨។ (មិថុនា)
- ក្រសួងផែនការផ្ញើសេចក្តីព្រាងចុងក្រោយនៃ ផ.យ.អ.ជ. ទៅទីស្តីការគណៈរដ្ឋមន្ត្រី។ (កក្កដា)

# ២. ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ត)

## ដំណើរការរៀបចំ

- ❑ កិច្ចប្រជុំបច្ចេកទេស នៅទីស្ដីការគណៈរដ្ឋមន្ត្រី ពិនិត្យមើលសេចក្ដីព្រាង ផ.យ.អ.ជ.។ (តុលា-ធ្នូ)
- ❑ គណៈរដ្ឋមន្ត្រីអនុម័ត សេចក្ដីព្រាង ផ.យ.អ.ជ.។ (តុលា-ធ្នូ)
- ❑ រដ្ឋសភា និងព្រឹទ្ធសភា អនុម័តលើសេចក្ដីព្រាង ផ.យ.អ.ជ. ២០២៤-២០២៨។ (តុលា-ធ្នូ)
- ❑ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឡាយព្រះហស្ថលើព្រះរាជក្រម សម្រាប់ការអនុវត្ត ផ.យ.អ.ជ.។

# ៣- ការងាររៀបចំ កម្មវិធីសាធារណៈ ៣ឆ្នាំរំកិល

## សាវតារនៃការរៀបចំក.វ.ស. ៣ឆ្នាំរំកិល

### ប្រព័ន្ធទិន្នន័យ
### កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល




-ក.វ.ស. ៣ឆ្នាំរំកិល ១៩៩៦-១៩៩៨ ជាឯកសារក.វ.ស. ៣ឆ្នាំរំកិល លើកទី១

-ក.វ.ស. ៣ឆ្នាំរំកិល ២០២៥-២០២៧ ជាឯកសារក.វ.ស. ៣ឆ្នាំរំកិល លើកទី៣០

# ៣- ការរៀបចំ កម្មវិធីសាធារណៈ ៣ឆ្នាំរំកិល (ត)

**គោលបំណងរបស់ ក.វ.ស. ៣ឆ្នាំរំកិល**

- បង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ន ដើម្បីអនុវត្តគោលនយោបាយអាទិភាពជាតិ ដែលមានចែងក្នុងកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ធ្វើជាធាតុចូលសម្រាប់ការរៀបចំ (១) ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (២) ក្របខ័ណ្ឌចវិការយៈពេលមធ្យម និង(៣)ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

# ៣- ការរៀបចំ កម្មវិធីសាធារណៈ ៣ឆ្នាំរំកិល (ត)

១. ការជូនដំណឹងដល់ក្រសួង ស្ថាប័នអំពីការរៀបចំព័ត៌មានគម្រោងដាក់ក្នុងប្រព័ន្ធទិន្នន័យក.វ.ស.៣ឆ្នាំរំកិល
២. ទទួលធាតុចូល(ព័ត៌មានគម្រោង)ពីក្រសួង ស្ថាប័ន
៣. ការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើបញ្ជីគម្រោងក្នុងក.វ.ស.៣ឆ្នាំរំកិល
៤. ការពិភាក្សាជាមួយក្រសួង ស្ថាប័នលើយោបល់ដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការបន្ថែមគម្រោង ឬកែសម្រួលព័ត៌មានរបស់គម្រោង
៥. ការរៀបចំសេចក្តីព្រាងក.វ.ស.៣ឆ្នាំរំកិល
៦. ការពិនិត្យ និងកែសម្រួលសេចក្តីព្រាងក.វ.ស.៣ឆ្នាំរំកិល ដឹកនាំដោយក្រសួងផែនការ និង
៧. ការពិនិត្យ កែសម្រួល និងឯកភាពលើសេចក្តីព្រាងក.វ.ស.៣ឆ្នាំរំកិល តាមរយៈយន្តការទីស្តីការគណៈរដ្ឋមន្ត្រី។

# ៤- ការទារតាមដានត្រួតពិនិត្យ និងវាយតម្លៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.)

- គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.) គឺជាកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ហើយរដ្ឋទាំងអស់ដែលជាសមាជិករបស់អង្គការនេះ មានភារកិច្ចចូលរួមអនុវត្តដើម្បីឱ្យសម្រេចបានបណ្តាគោលដៅនានាតាមគោលដៅកំណត់។
- គ.អ.ច. មានគោលដៅចំនួន១៧ ចំណុចដៅចំនួន១៦៩ និងសូចនាករចំនួន២៣២។
- កម្ពុជាបានដំណើរការសិក្សា និងពិនិត្យជ្រើសរើសគោលដៅ ចំណុចដៅ និងសូចនាករ ដែលសមស្រប និងអាចអនុវត្តបាននៅកម្ពុជា។
- អគ្គនាយកដ្ឋានផែនការក្រសួងផែនការ បានទទួលភារកិច្ចដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងទៀតរៀបចំធ្វើមូលដ្ឋានីយកម្ម គ.អ.ច. មកក្នុងបរិការណ៍កម្ពុជា និងបានរៀបចំចេញជាក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៦-២០៣០។

# ៤- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.)(ត)

- គ.អ.ច.ក. មានគោលដៅចំនួន១៨ ចំណុចដៅចំនួន៨៨ និងសូចនាករចំនួន១៤៨។
- នៅឆ្នាំ២០២១ ដោយសារផលប៉ះពាល់នៃការការរីករាលដាលនៃកូវីដ-១៩, សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន, និងវិបត្តិសកលនានា រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការកែសម្រួលបញ្ជីគោលដៅ ចំណុចដៅ និងសូចនាកររបស់ គ.អ.ច.ក.។
  - ដកចេញនូវសូចនាករ និងចំណុចដៅទាំងឡាយណាដែលមិនមានប្រភពទិន្នន័យគាំទ្រ
  - កែសម្រួលតម្លៃចំណុចដៅរបស់សូចនាករ តាមស្ថានភាពជាក់ស្តែង នៃសង្គមសេដ្ឋកិច្ចកម្ពុជា និង
  - ពិចារណាបន្ថែមសូចនាករមួយចំនួនដែលរួមចំណែកធ្វើឱ្យសម្រេចបានគោលដៅនានា នៃ គ.អ.ច.ក.។
  - ក្រោយការកែសម្រួល គ.អ.ច.ក. មានគោលដៅចំនួន១៨ ចំណុចដៅចំនួន៩៥ និងសូចនាករមានចំនួន១៨៥។

## សាវតានៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

**2006**
ក្រសួងផែនការ ដោយមានការគាំទ្រពី GIZ បានរៀបចំនីតិវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រជាស្តង់ដាររួមមួយ

**2007**
កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្របានអនុវត្ត តាមតំបន់គ្របដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាល

**2010**
កម្មវិធីបានគ្របដណ្តប់តំបន់ទីជនបទ។ទិន្នន័យបានធ្វើបច្ចុប្បន្នភាពតាមជុំរៀងរាល់បីឆ្នាំម្តង។

**2011**
អនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

**2016**
កម្មវិធីបានពង្រីកវិសាលភាពគ្រប់ដណ្តប់គ្រប់តំបន់ ទាំងទីជនបទ និងទីប្រជុំជន

**2020**
ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំ ត្រូវបានអនុវត្តជាប្រចាំ

**2022**
មានការកែសម្រួលប្រព័ន្ធដាក់ពិន្ទុ, រៀបចំការចុះឈ្មោះអ្នកផ្ទុកមេរោគអេដស៍, ពង្រីកវិសាលភាពទៅដល់គ្រួសារងាយរងហានិភ័យ

**2023**
ដាក់ឲ្យដំណើរការយន្តការគ្រប់គ្រងមតិជំទាស់ និងសំណូមពរ និងប្រព័ន្ធតាមដានត្រួតពិនិត្យបែបឌីជីថល

2005 2007 2009 2011 2013 2015 2017 2019 2021 2023



idpoor.gov.kh fb.com/IDPoor Cambodia https://t.me/idpoorcambodia 023 726 814 youtube.com/IDPoor Cambodia

# អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាយន្តការសម្រាប់កម្មវិធីគាំពារសង្គម

ក្រសួងផែនការ

ក្រសួង
ផែនការ

ទិន្នន័យចែករំលែកតាមរយៈ
ការផ្ញើសន្ទានកម្ម (API)



ក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិ
គាំពារសង្គម

SOCIAL PROTECTION IN CAMBODIA

**ការចុះបញ្ជី៖**

- គ្រួសារក្រីក្រ (> 80ម៉ឺន)
- គ្រួសារងាយរងហានិភ័យ (> 40ម៉ឺន)
- អ្នករស់នៅជាមួយមេរោគអេដស៍ (> 2ម៉ឺន)
- > 1.2 លានគ្រួសារ

ក្រសួង
សុខាភិបាល

ក្រសួងសង្គម
កិច្ច អតីតយុទ្ធ
ជន និងយុវនីតិ
សម្បទា

ក្រសួងការងារ
និង
បណ្តុះបណ្តាល
វិជ្ជាជីវៈ

ផ្តល់សេវាជូនដល់

អង្គការសង្គម
ស៊ីវិល

# កម្មវិធីជំនួយសង្គមផ្សេងៗ ដែលប្រើប្រាស់ទិន្នន័យរបស់ក្រសួងផែនការ

## ការគាំពារសង្គមដោយការឆ្លើយតបនឹងគ្រោះអាសន្ន:

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រកំឡុងពេលកូវីដ១៩
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ដោយទឹកជំនន់ និងសម្ពាធអតិផរណា

## ជំនួយសង្គម:

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រីក្រ អាយុក្រោម២ឆ្នាំ
- ទទួលបានសេវាសុខភាពសាធារណៈមិនបង់ថ្លៃពីមូលនិធិសមធម៌សុខាភិបាល
- ការផ្តល់អាហារនៅតាមសាលារៀន
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- កម្មវិធីកញ្ចប់គ្រួសារនាពេលអនាគត

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA



# រចនាសម្ព័ន្ធនៃការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

អគ្គនាយកដ្ឋានផែនការ
នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

មន្ទីរផែនការ
២៥ រាជធានី ខេត្ត

- រៀបចំយុទ្ធសាស្រ្ត
- កសាងសមត្ថភាព
- គ្រប់គ្រងទិន្នន័យ
- តាមដានត្រួតពិនិត្យ



១៦៥២ ក្រុមការងារឃុំ សង្កាត់
និងក្រុមប្រឹក្សាឃុំ សង្កាត់

- ចុះបញ្ជីគ្រួសារ
- ដកគ្រួសារចេញ
- កែសម្រួលព័ត៌មានគ្រួសារ



~១៤៤០០ ភូមិដែលអាជ្ញាធរ និង
ប្រជាពលរដ្ឋ, ស្ថាប័នរដ្ឋាភិបាល,
សង្គមស៊ីវិល, អង្គការNGO

- ដាក់ពាក្យស្នើសុំ
- ផ្តល់មតិជំទាស់

NGO= Non Governmental Organization

# កិច្ចដំណើរការ – ៥ជំហានដើម្បីចុះឈ្មោះរបស់គ្រួសារថ្មី







## ការចុះឈ្មោះថ្មី នៃគ្រួសារក្រីក្រ ឬ ងាយរងហានិភ័យ

ដំណើរការផ្តល់បណ្ណសមធម៌ (EC)

ជំហានទី១ ការដាក់ពាក្យសុំសម្ភាសន៍គ្រួសារ

ជំហានទី២ ក្រុមការងារឃុំសម្រេចលើពាក្យស្នើសុំ

ជំហានទី៣ ក្រុមការងារឃុំចុះសម្ភាសន៍គ្រួសារ

ជំហានទី៤ ក្រុមប្រឹក្សាឃុំធ្វើសុពលភាពលទ្ធផលសម្ភាសន៍

ជំហានទី៥ ផលិត និង ចែកបណ្ណធម៌

# ការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ



idpoor.gov.kh

**ក្រុមការងារឃុំ/សង្កាត់**
**និង**
**ក្រុមប្រឹក្សាឃុំ/សង្កាត់**

## ដំណើរការកែសម្រួលព័ត៌មានគ្រួសារ

ជំហានទី១៖ ការដាក់ពាក្យនិងទទួលពាក្យពាក្យស្នើសុំកែសម្រួលព័ត៌មាន

ជំហានទី២៖ ក្រុមការងារឃុំសង្កាត់ ពិនិត្យនិងសម្រេចលើពាក្យស្នើសុំកែសម្រួលព័ត៌មាន

ជំហានទី៣៖ ត្រូវប្តូរបណ្ណសមធម៌ថ្មីក្នុងករណីផ្លាស់ប្តូរមេគ្រួសារ

# ការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ



idpoor.gov.kh

ក្រុមការងារឃុំ/សង្កាត់
និង
ក្រុមប្រឹក្សាឃុំ/សង្កាត់

## ការដកគ្រួសារចេញពីបញ្ជី

ជំហានទី១ ការដាក់ពាក្យនិងទទួលពាក្យស្នើសុំដកគ្រួសារ

ជំហានទី២ ក្រុមប្រឹក្សាឃុំ/សង្កាត់ពិនិត្យ សម្រេចលើពាក្យស្នើសុំដកគ្រួសារ

- ដកគ្រួសារចេញតាមសំណើរ ធ្វើការសម្ភាសន៍ឡើងវិញ ឬបដិសេធពាក្យស្នើសុំ

ប្រសិនបើសម្ភាសន៍សារឡើងវិញ

អនុវត្តតាមជំហានទី៣-៤ នៃដំណើរការផ្តល់បណ្ណ



idpoor.gov.kh fb.com/IDPoor Cambodia https://t.me/idpoorcambodia 023 726 814 youtube.com/IDPoor Cambodia

# ៦- ការខារអាហារូបត្ថម្ភ

## ប្រវត្តិដើម៖

- ការងារលើកកម្ពស់អាហាររូបត្ថម្ភគឺជាកម្មវិធីលុបបំបាត់ជាតិអ៊ីយ៉ូត និងបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដើម្បីលើកកម្ពស់អាហារូបត្ថម្ភរបស់កុមារ និងប្រជាជនកម្ពុជា។
- ក្រសួងផែនការត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់ភារកិច្ចជាអ្នកសម្របសម្រួលកម្មវិធី ស័កម្មភាពអាហារូបត្ថម្ភជាតិ។
- កម្មវិធីលើកកម្ពស់អាហារូបត្ថម្ភ ចាប់ផ្តើមពីឆ្នាំ១៩៩៥ ដោយបានបង្កើតអនុគណៈកម្មការជាតិលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដនៅកម្ពុជា ឆ្នាំ១៩៩៦ និងបង្កើតក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ (មាន១២ស្ថាប័ន) ឆ្នាំ១៩៩៨។
- កម្មវិធីនេះ មានការសហការជាមួយក្រសួងសុខាភិបាល និងគាំទ្រដោយអង្គការ WHO UNICEF និង GIZ/RACHA។

# ៦- ការខារអាហារូបត្ថម្ភ (ត)

សកម្មភាពរបស់ក្រសួងផែនការក្នុងកម្មវិធីលើកម្ពស់អាហារូបត្ថម្ភ រួមមាន៖

- ចូលរួមក្នុង កម្មវិធីបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិលជាសកល
- កម្មវិធីបញ្ចូលជាតិដែកក្នុងទឹកត្រី ទឹកស៊ីអ៊ីវ
- កម្មវិធីបញ្ចូលមីក្រូសារជាតិក្នុងអង្ករ និង
- កម្មវិធីបញ្ចូលវិតាមីនបេ១ ក្នុងអំបិលអ៊ីយ៉ូដ (កំពុងសិក្សា)។

# ៦- ការខារអាហារូបត្ថម្ភ (ត)

## លទ្ធផលសម្រេចបាន ក្នុងឆ្នាំ២០២៣៖

- ផលិតអំបិលអ៊ីយ៉ូដបាន ៣២ ៥០០តោន។
- អាត្រាប្រើប្រាស់អំបិលអ៊ីយ៉ូដតាមគ្រួសារ ៤៩% (CDHS 2021-2022)។
- ផលិតទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក បាន៨០១ ៥០០លីត្រ។
- ផលិតអង្ករបញ្ចូលមីក្រូសារជាតិបាន៩០០តោន ពង្រីកបាន៣ ខេត្ត ផ្តល់អាហារតាមសាលាបឋមសិក្សា បានចំនួន២២២ សាលា ដែលមានសិស្សចំនួន ៥៦ ០០០នាក់។

# ៧- ការងារផែនការថ្នាក់ក្រោមជាតិ

- គឺជាការដឹកនាំ ការរៀបចំ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល នៅថ្នាក់ក្រោមជាតិ ក្នុងនោះ មានការរៀបចំ និងបង្កើតឯកសារសេចក្តីណែនាំស្តីពីការរៀបចំ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល នៅថ្នាក់ក្រោមជាតិ និង ការរៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យមូលដ្ឋាន ឃុំ សង្កាត់។
- ឯកសារដែលបានរៀបចំរួមមាន៖
  - សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
  - សេចក្តីណែនាំ ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគ បីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
  - ឯកសារជំនួយស្មារតី ស្តីពីបច្ចេកទេសសម្រាប់គ្រប់គ្រងទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ។
  - សេចក្តីព្រាងបឋមសេចក្តីណែនាំ ស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃដំណើរការរៀបចំ និងអនុវត្តផែនការ នៅថ្នាក់ក្រោមជាតិ។

# ៧- ការវាស់វែងភាពក្រីក្រ

- ក្រសួងផែនការ ដោយមានអគ្គនាយកដ្ឋានផែនការជាសេនាធិការ បានសហការជាមួយធនាគារពិភពលោក រៀបចំវាស់វែងភាពក្រីក្ររបស់ប្រជាជនកម្ពុជា ដោយប្រើប្រាស់ទិន្នន័ពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា។
- ការងារដែលសម្រេចបាន រួមមាន៖
  - គណនាកម្រិតនៃភាពក្រីក្រ ឆ្នាំ២០០៤ ដោយប្រប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤។
  - គណនាកម្រិតនៃភាពក្រីក្រ ឆ្នាំ២០០៧ ដោយប្រប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៧។
  - រៀបចំវិធីសាស្រ្តថ្មីសម្រាប់គណនាភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០១៣ និង គណនាកម្រិតនៃភាពក្រីក្រ សម្រាប់ឆ្នាំ២០១៣ ដោយប្រប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៣។

# ៨- ការវាស់វែងភាពក្រីក្រ

- គណនាកម្រិតនៃភាពក្រីក្រ ឆ្នាំ២០១៩-២០២០ ដោយប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩-២០២០។
- គណនាកម្រិតនៃភាពក្រីក្រ ឆ្នាំ២០២១ ដោយប្រប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២១ (មិនបានផ្សព្វផ្សាយ)។
- រៀបចំផែនទីនៃភាពក្រីក្រ ដោយប្រើប្រាស់ទិន្នន័យពីជំរឿន និងអង្កេត (ជិតបញ្ចប់ហើយ)។

- កំពុងសហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សិក្សាពីការវាស់វែងភាពក្រីក្ររបស់ប្រជាជនកម្ពុជាផ្អែកលើពហុសមាសភាគ។
- បានសហការជាមួយអង្គការយូនីសេហ្វ វាស់វែងភាពក្រីក្ររបស់កុមារកម្ពុជាផ្អែកលើពហុសមាសភាគ ឆ្នាំ២០១៧ និងឆ្នាំ២០២១។

## ៩- ទិសដៅត្រូវអនុវត្តបន្ត ឆ្នាំ២០២៤

- បន្តរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨។
  - សុំការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា។
  - សុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ និងឡាយព្រះហស្តលេខាពីព្រះមហាក្សត្រ។
  - បោះពុម្ព និងផ្សព្វផ្សាយ
- រៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៦-២០២៨។
- ផ្សព្វផ្សាយរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០២៣។
- បន្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
- រៀបចំវាស់វែងភាពក្រីក្ររបស់ប្រជាជនកម្ពុជា ដោយប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៣។
- បន្តការងារអាហារូបត្ថម្ភ និងការងារផែនការថ្នាក់ក្រោមជាតិ។

# សូមអរគុណ !